

# NURSE-ON-CALL

## 1300 60 60 24

គំនិតផ្ដួចផ្ដើមផ្នែកសុខភាពរបស់រដ្ឋាភិបាលរដ្ឋវិចថូរៀ **NURSE-ON-CALL** គឺសេវាកម្មទូរសព្ទដែលផ្ដល់ដំបូន្មានសុខភាពដោយអ្នកជំនាញភ្លាមៗ ពីគិលានុបដ្ឋាកដែលចុះបញ្ជីស្របច្បាប់ **មានជូន 24 ម៉ោង/7 ថ្ងៃ។**

ហៅទូរសព្ទលេខ **1300 60 60 24** ដោយបង់តម្លៃការហៅទូរសព្ទក្នុងតំបន់ ពីគ្រប់ទីកន្លែងក្នុងរដ្ឋវិចថូរៀ*

*ការហៅទូរសព្ទពីទូរសព្ទដៃ អាចគិតថ្លៃក្នុងអត្រាខ្ពស់ជាងនេះ។ NURSE-ON-CALL ផ្ដល់ជូនដោយ Healthdirect Australia ក្នុងនាមរដ្ឋាភិបាលរដ្ឋវិចថូរៀ។


# NURSE-ON-CALL

## 1300 60 60 24


## ភាពងាយស្រួលក្នុងការទាក់ទងពឹងពាក់

### តើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ទេ?

ហៅទូរសព្ទទៅ TIS International តាមលេខ **131 450** ហើយស្នើសុំនិយាយជាមួយ **NURSE-ON-CALL**។

### តើខ្ញុំត្រូវប្រើប្រាស់សេវាកម្មដោយរបៀបណា ប្រសិនបើខ្ញុំមានបញ្ហាក្នុងការស្ដាប់ ឬនិយាយ?

សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ មានផ្ដល់ជូនដើម្បីជួយដល់អ្នកហៅទូរសព្ទដែលមានបញ្ហាក្នុងការស្ដាប់ ឬការនិយាយ។ អ្នកប្រើប្រាស់ Voice Relay (ឧបករណ៍ប្រាស្រ័យទាក់ទងសម្រាប់ជនពិការ) គួរតែទូរសព្ទលេខ **1800 555 727** ខណៈពេលដែលអ្នកប្រើប្រាស់ Teletypewriter (ឧបករណ៍ប្រាស្រ័យទាក់ទងដោយផ្ញើសារសម្រាប់ជនពិការ) (TTY) គួរតែទូរសព្ទលេខ **1800 555 677** ហើយស្នើសុំឱ្យគេភ្ជាប់ទៅ **NURSE-ON-CALL**។ អ្នកប្រើប្រាស់ការប្រាស្រ័យទាក់ទងជាមួយជនពិការតាមអ៊ីនធើណិត អាចប្រើប្រាស់បណ្ដាញទូរសព្ទជំនួយ តាមរយៈសេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ ។

សម្រាប់ព័ត៌មានបន្ថែមអំពី **NURSE-ON-CALL** សូមចូលមើលគេហទំព័រ **healthdirect.gov.au/nurse-on-call**


អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។ © រដ្ឋវិចថូរៀ អូស្រ្តាលី ក្រសួងសុខាភិបាល ខែសីហា ឆ្នាំ 2021។ បោះពុម្ពដែលគ្រប់គ្រងដោយ Finsbury Green។ (DH 2106065)។




# ពលរដ្ឋវិចថូរៀគ្រប់រូបមាន NURSE-ON-CALL


## 1300 60 60 24




ព័ត៌មានស្ដីពីសុខភាពតាមទូរសព្ទ អាចរកបាន 24 ម៉ោង/7 ថ្ងៃ។

**healthdirect.gov.au/nurse-on-call**

Department of Health

# យើងនៅទីនោះ សម្រាប់ពេលដែលអ្នក ត្រូវការយើង

**NURSE-ON-CALL** ភ្ជាប់អ្នកដោយផ្ទាល់ ជាមួយគិលានុបដ្ឋាកដែលចុះបញ្ជីស្របច្បាប់ ដើម្បីទទួលបានដំបូន្មានសុខភាពប្រកបដោយវិជ្ជាជីវៈ និងការយកចិត្តទុកដាក់គ្រប់ពេលវេលា។ **សម្រាប់គ្រាអាសន្ន អ្នកគួរតែទូរសព្ទទៅលេខសូន្យបីដង (000)** ប៉ុន្តែនៅពេលផ្សេងទៀត **NURSE-ON-CALL** អាចជាជម្រើសដ៏ល្អបំផុតរបស់អ្នក សម្រាប់ដំបូន្មានសុខភាព។

ឧទាហរណ៍ អ្នកអាចទូរសព្ទនៅពេល៖

- អ្នក ឬនរណាម្នាក់ដែលអ្នកកំពុងថែទាំមានអារម្មណ៍មិនស្រួលខ្លួន
- នៅកណ្ដាលអាធ្រាត្រ ហើយអ្នកមិនប្រាកដច្បាស់ថាអ្នកគួរតែស្វែងរកជំនួយពេទ្យឬយ៉ាងណា
- អ្នកនៅឆ្ងាយពីផ្ទះ ឬស្ថិតនៅទីកន្លែងឆ្ងាយពីជំនួយពេទ្យ
- អ្នកគ្រាន់តែចង់បានដំបូន្មាន ឬព័ត៌មានអំពីសេវាកម្មសុខភាពក្នុងតំបន់របស់អ្នក។

សូមកុំមានអារម្មណ៍ស្ទាក់ស្ទើរ ដោយទូរសព្ទមក **NURSE-ON-CALL** ដើម្បីពិភាក្សាអំពីបញ្ហាទាក់ទងនឹងសុខភាព។ គ្រាន់តែទូរសព្ទមកលេខ **1300 60 60 24** ពីគ្រប់ទីកន្លែងក្នុងរដ្ឋវិចថូរៀ ដោយបង់តម្លៃការហៅទូរសព្ទក្នុងតំបន់*។



# តើមានអ្វីកើតឡើងនៅពេលខ្ញុំទូរសព្ទសុំដំបូន្មានសុខភាព?

**ជំហានទី 1** – គិលានុបដ្ឋាកដែលចុះបញ្ជីស្របច្បាប់ នឹងឆ្លើយតបការហៅទូរសព្ទរបស់អ្នក ហើយប្រមូលព័ត៌មានលម្អិតចាំបាច់មួយចំនួន។

**ជំហានទី 2** – បន្ទាប់មក គិលានុបដ្ឋាកនឹងសួរអ្នកនូវសំណួរមួយចំនួនអំពីរោគសញ្ញារបស់អ្នក និងបញ្ហាផ្សេងទៀតទាក់ទងនឹងសុខភាពរបស់អ្នក។

**ជំហានទី 3** – នៅចុងបញ្ចប់នៃការហៅទូរសព្ទ គិលានុបដ្ឋាកអាចណែនាំពីវិធីដែលអ្នកអាចថែទាំខ្លួនអ្នក ណែនាំអ្នកឱ្យទាក់ទងវេជ្ជបណ្ឌិតព្យាបាលរោគទូទៅរបស់អ្នក ឬក្នុងករណីដែលស្ថានភាពរបស់អ្នកធ្ងន់ធ្ងរខ្លាំង បញ្ជូនការហៅទូរសព្ទរបស់អ្នកទៅ **លេខសូន្យបីដង (000)**។

សូមកត់សម្គាល់ថា គិលានុបដ្ឋាកមិនផ្តល់ការធ្វើរោគវិនិច្ឆ័យពេញលេញ អំពីរោគសញ្ញារបស់អ្នកទេ។

គិលានុបដ្ឋាកប្រើប្រាស់ព័ត៌មានសុខភាពទាន់បច្ចុប្បន្នភាពបំផុត ដែលអាចរកបាន ដោយផ្ដល់ជូនអ្នកនូវដំបូន្មានដែលមានគុណភាពខ្ពស់បំផុត សម្រាប់ប្រធានបទដែលអ្នកកំពុងហៅទូរសព្ទ។

ជាការពិតណាស់ ព័ត៌មានទាំងអស់ដែលអ្នកផ្ដល់ឱ្យនៅតែត្រូវបានរក្សាការសម្ងាត់ ហើយកំណត់ត្រាត្រូវបានរក្សាទុកប្រកបដោយសុវត្ថិភាពពេញលេញ។

# ដំបូន្មានសុខភាព និងអ្វីៗជាច្រើនទៀត

**NURSE-ON-CALL** ក៏អាចផ្តល់ជូនអ្នកនូវព័ត៌មានទាក់ទងនឹងសុខភាពផ្សេងទៀតផងដែរ ដូចជាព័ត៌មានលម្អិតអំពីសេវាកម្មសុខភាពនៅក្នុងតំបន់របស់អ្នក ឬលេខទូរសព្ទនៃបណ្ដាញទូរសព្ទជំនួយផ្សេងទៀត។

**NURSE-ON-CALL** ផ្ដល់ជូនពលរដ្ឋវិចថូរៀទាំងអស់នូវសេចក្ដីស្ងប់ចិត្ត ដោយដឹងថាការទទួលបានដំបូន្មានសុខភាពប្រកបដោយវិជ្ជាជីវៈ គឺងាយស្រួលទេដោយគ្រាន់តែហៅទូរសព្ទប៉ុណ្ណោះ មិនថាថ្ងៃ ឬយប់ឡើយ។

*ការហៅទូរសព្ទពីទូរសព្ទដៃ អាចគិតថ្លៃក្នុងអត្រាខ្ពស់ជាងនេះ។ NURSE-ON-CALL ផ្ដល់ជូនដោយ Healthdirect Australia ក្នុងនាមរដ្ឋាភិបាលរដ្ឋវិចថូរៀ។



ដំបូន្មានសុខភាព 24 ម៉ោង សម្រាប់ពលរដ្ឋវិចថូរៀគ្រប់ទាំងអស់

**NURSE-ON-CALL**

**1300 60 60 24**

## សម្រាប់ស្ថានភាពអាសន្ន ឬគ្រោះថ្នាក់ដល់អាយុជីវិត អ្នកគួរតែទូរសព្ទទៅលេខសូន្យបីដង (000) ជានិច្ច